ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០២៨ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើស្តង់ដារគណនេយ្យការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជា
## (ស.រ.ហ.ក)

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និង អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីសមាសភាពនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ
- បានឃើញអនុក្រឹត្យលេខ ១៨/អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ

# ស ម្រេ ច

**ប្រការ ១.-**

ដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជា(**ស.រ.ហ.ក**) សម្រាប់គ្រប់វិស័យអាជីវកម្មនៅកម្ពុជា ដោយឱ្យអនុវត្តទាំងស្រុងតាមរាល់ស្តង់ដារអន្តរជាតិ ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ (International Accounting Standard Board) ដោយរាប់បញ្ចូលទាំងការបកស្រាយ ទាំងការធ្វើបច្ចុប្បន្នកម្មដែលអាចកើតមានឡើងនៅគ្រប់កាលៈទេសៈ ចំពោះស្តង់ដារអន្តរជាតិនីមួយៗនោះផង ។

**ប្រការ ២.-**

រាល់សហគ្រាសធុនធំនិងមធ្យមដែលជាប់កាតព្វកិច្ច តាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តឱ្យបានពេញលេញនូវស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជា(**ស.រ.ហ.ក**) ដែលចែងនៅប្រការ១ខាងលើ តាមសេចក្តីជូនដំណឹងរបស់ក្រុមប្រឹក្សាជាតិគណនេយ្យ(**ក.ជ.គ**) ។

សហគ្រាសដទៃទៀតក្រៅពីនេះក៏អាចអនុវត្តតាម**ស.រ.ហ.ក**នេះបានដែរ ដោយពុំមានការខុសទាស់ឡើយ កាលបើសហគ្រាសទាំងនោះយល់ឃើញថាជាការចាំបាច់ នៅក្នុងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ។

**ប្រការ ៣.-**

ក្រុមប្រឹក្សាជាតិគណនេយ្យ(**ក.ជ.គ**)មានសិទ្ធិសម្រេចជ្រើសរើស ចេញសេចក្តីជូនដំណឹង និងផ្សព្វផ្សាយតាមគ្រប់មធ្យោបាយ នូវស្តង់ដារអន្តរជាតិទាំងឡាយដែលត្រូវបានចេញផ្សាយដោយក្រុមប្រឹក្សាគណនេយ្យអន្តរជាតិរួចហើយនោះដោយគ្រាន់តែប្តូរចំណងជើងទៅជាស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជា(**ស.រ.ហ.ក**) ឱ្យដល់គ្រប់សហគ្រាសដែលមានកាតព្វកិច្ចអនុវត្តតាម និងមានតម្រូវការអនុវត្តតាម ។

ទន្ទឹមគ្នានេះ ក្រុមប្រឹក្សាជាតិគណនេយ្យមានភារកិច្ចចាត់ចែងការបកប្រែសម្រួល នូវស្តង់ដារអន្តរជាតិនិមួយៗនោះជាមួយនឹងការបកស្រាយនិងបច្ចុប្បន្នកម្មជាបណ្តើរៗ មកជាភាសាជាតិ ។

**ប្រការ ៤.-**

ការមិនអនុវត្តតាមបទប្បញ្ញត្តិនៃប្រកាសនេះនឹងត្រូវចាត់ទុកជាការល្មើស ចំពោះមាត្រា ១៨ និង ១៩ នៃច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ ។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខ ២២១ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការដាក់ឱ្យប្រើស្តង់ដារគណនេយ្យកម្ពុជា(**ស.គ.ក**) និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជា (**ស.រ.ហ.ក**) ត្រូវបានចាត់ទុកជានិរាករណ៍ និងជំនួសទាំងស្រុងដោយប្រកាសនេះ ។

ប្រការ ៦.-

អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ប្រធានវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា( វ.គ.ស.ក) និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ព្រមទាំងសហគ្រាសធុនធំនិងមធ្យមដែលជាប់កាតព្វកិច្ចតាមប្រការ២ខាងលើ ត្រូវអនុវត្តតាមតួនាទីរៀងៗខ្លួននូវប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែមករា ឆ្នាំ២០០៩

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ ស.ហ.វ

  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់ក្រសួង-ស្ថាប័ននិងអាជ្ញាធរពាក់ព័ន្ធ
- គ្រប់សាលាខេត្ត-ក្រុង

  "ដើម្បីជូនជ្រាបនិងសហការអនុវត្ត"
- ដូចប្រការ៦

  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ
- រាជកិច្ច